**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ៖ ៤៤៤ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៣

# ប្រកាស
# ស្តីពី
# ភ្នាក់ងារសេវាកម្មពន្ធដារ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ/បក ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការដំឡើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- យោងតាមការចាំបាច់នៃការងារគ្រប់គ្រងប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

## សម្រេច

### ប្រការ ១.- គោលបំណង

ប្រកាសនេះ មានគោលបំណងកំណត់លក្ខណៈវិនិច្ឆ័យ និងគ្រប់គ្រងបុគ្គលដែលធ្វើសកម្មភាពអាជីវកម្មជាភ្នាក់ងារសេវាកម្មពន្ធដារ ដើម្បីធានាការផ្តល់សេវាឱ្យអ្នកជាប់ពន្ធរបស់ភ្នាក់ងារសេវាកម្មពន្ធដារ ប្រកបដោយគុណភាព និងវិជ្ជាជីវៈ និងដើម្បីឱ្យអ្នកជាប់ពន្ធនិងភ្នាក់ងារសេវាកម្មពន្ធដារ អនុវត្តត្រឹមត្រូវ ទាន់ពេលវេលា និងទប់ស្កាត់បាននូវអំពើគេចវេះពន្ធ ។

### ប្រការ ២.- វិសាលភាពនៃការផ្តល់សេវាតាមរបបកំណត់ពន្ធ

១- ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះភ្នាក់ងារសេវាកម្មពន្ធដារ ដែលធ្វើការផ្គត់ផ្គង់សេវាទាក់ទិនពន្ធដារដល់អ្នកជាប់ពន្ធដែលចុះបញ្ជីបង់ពន្ធតាមរបបពិត ។

២- ភ្នាក់ងារសេវាកម្មពន្ធដារ អាចធ្វើការផ្គត់ផ្គង់សេវាទាក់ទិនពន្ធដារដល់អ្នកជាប់ពន្ធតាមរបបពិតផង និងរបបម៉ៅការផង ។ អ្នកជាប់ពន្ធតាមរបបម៉ៅការ អាចទទួលបានការផ្គត់ផ្គង់សេវាទាក់ទិនពន្ធដារ ដោយបុគ្គលដទៃទៀតក្រៅពីភ្នាក់ងារសេវាកម្មពន្ធដារ ។

### ប្រការ ៣.- និយមន័យ

សម្រាប់គោលដៅនៃប្រកាសនេះ ÷

១- ពាក្យ "បុគ្គល" សំដៅដល់ រូបវន្តបុគ្គល នីតិបុគ្គល និងក្រុមអាជីវកម្ម ដូចមានចែងក្នុងមាត្រា ៣ នៃច្បាប់ស្តីពីសារពើពន្ធ ។

២- ពាក្យ "ភ្នាក់ងារសេវាកម្មពន្ធដារ" សំដៅដល់ បុគ្គលដែលទទួលបានការអនុញ្ញាតជាភ្នាក់ងារសេវាកម្មពន្ធដារ ពីអគ្គនាយកដ្ឋានពន្ធដារ ។

៣- ពាក្យ "ស្ថាប័នមានសមត្ថកិច្ច" សំដៅដល់ ស្ថាប័នឬអាជ្ញាធរមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។

៤- ពាក្យ "អាជ្ញាប័ណ្ណ" សំដៅដល់ អាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ ដែលចេញដោយ អគ្គនាយកដ្ឋានពន្ធដារ ។

### ប្រការ ៤.- ការបំពេញកាតព្វកិច្ចសារពើពន្ធ

១- អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក (នាយក បណ្ណាធិការ កម្មសិទ្ធិករ គណនេយ្យករ និងបុគ្គលិកទទួលសិទ្ធិរបស់សហគ្រាស) អាចបំពេញបែបបទពន្ធដារ ដាក់លិខិតប្រកាសពន្ធ បង់ប្រាក់ពន្ធប្រចាំខែ ប្រចាំឆ្នាំ និង ធ្វើទំនាក់ទំនងជាមួយរដ្ឋបាលសារពើពន្ធ ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធសម្រាប់សហគ្រាសខ្លួនផ្ទាល់ និងមិនត្រូវបានចាត់ទុកជាភ្នាក់ងារសេវាកម្មពន្ធដារឡើយ ។ និយោជក ឬនិយោជិតរបស់សហគ្រាស ត្រូវពាក់ប័ណ្ណសម្គាល់ក្នុងពេលធ្វើទំនាក់ទំនងជាមួយរដ្ឋបាលសារពើពន្ធ ។

២- បុគ្គលទាំងឡាយ ដែលទទួលបានអាជ្ញាប័ណ្ណជាភ្នាក់ងារសេវាកម្មពន្ធដារ ពីអគ្គនាយកដ្ឋានពន្ធដារ មានសិទ្ធិធ្វើជាអ្នកតំណាងជំនួសមុខឱ្យអ្នកជាប់ពន្ធ ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ បន្ទាប់ពីទទួលបានសិទ្ធិស្របច្បាប់ជាអ្នកតំណាងពីអ្នកជាប់ពន្ធ ។

៣- ភ្នាក់ងារសេវាកម្មពន្ធដារ អាចបំពេញសេវាកម្មជូនអ្នកជាប់ពន្ធ តាមរយៈបុគ្គលិករបស់ខ្លួនដោយមានលិខិតបញ្ជាក់ប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ និងត្រូវពាក់ប័ណ្ណសម្គាល់បុគ្គលិកភ្នាក់ងារសេវាកម្មពន្ធដារ ក្នុងពេលធ្វើទំនាក់ទំនងជាមួយរដ្ឋបាលសារពើពន្ធ ។

**ប្រការ ៥.- លក្ខណៈវិនិច្ឆ័យរបស់រូបវន្តបុគ្គលដើម្បីស្នើសុំប្រឡងជាភ្នាក់ងារសេវាកម្មពន្ធដារ**

រូបវន្តបុគ្គលដែលមានលក្ខណៈវិនិច្ឆ័យទាំងអស់ដូចខាងក្រោម អាចដាក់ពាក្យមកអគ្គនាយកដ្ឋានពន្ធដារ ដើម្បីស្នើសុំប្រឡងជាភ្នាក់ងារសេវាកម្មពន្ធដារ ÷

១- មានសញ្ជាតិខ្មែរ ឬជានិវាសនជនដែលមានលំនៅដ្ឋានជាប់លាប់នៅកម្ពុជា

២- មានអាយុចាប់ពី ១៨ឆ្នាំ ឡើងទៅ

៣- មានសញ្ញាបត្រចាប់ពីមធ្យមសិក្សាទុតិយភូមិ ឬដែលមានតម្លៃសមមូលឡើងទៅ

៤- មានសញ្ញាបត្រ ឬវិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ការសិក្សាជំនាញផ្នែក ច្បាប់ សេដ្ឋកិច្ច ពាណិជ្ជកម្ម ពន្ធដារ ឬជំនាញពាក់ព័ន្ធ ដែលសិក្សារយៈពេលចាប់ពី ៦ខែឡើងទៅ

៥- មានលិខិតថ្កោលទោសចេញដោយស្ថាប័នមានសមត្ថកិច្ច ។

**ប្រការ ៦.- ការប្រឡងជ្រើសរើស**

១- អគ្គនាយកដ្ឋានពន្ធដារ ត្រូវរៀបចំលិខិតបទដ្ឋាន សម្រាប់ការប្រឡងជ្រើសរើសភ្នាក់ងារសេវាកម្មពន្ធដារ យ៉ាងតិចមួយដងជារៀងរាល់ឆ្នាំ និងត្រូវជូនដំណឹងជាសាធារណៈអំពី កាលបរិច្ឆេទ ទីកន្លែង និងលក្ខខណ្ឌនានានៃការប្រឡងនេះយ៉ាងតិច ហុកសិប(៦០) ថ្ងៃ មុនកាលបរិច្ឆេទនៃការប្រឡង ។

២- អគ្គនាយកដ្ឋានពន្ធដារ ត្រូវរៀបចំលិខិតបទដ្ឋាន មុខវិជ្ជាប្រឡង និងនីតិវិធីសម្រាប់ការប្រឡងជ្រើសរើសភ្នាក់ងារសេវាកម្មពន្ធដារ និងបែបបទសម្រាប់ការទទួលពាក្យស្នើសុំប្រឡង ។

**ប្រការ ៧.- ការស្នើសុំអាជ្ញាប័ណ្ណដោយមិនចាំបាច់ប្រឡង**

ក្រុមហ៊ុននីតិបុគ្គល ក្រុមអាជីវកម្ម ព្រមទាំងរូបវន្តបុគ្គល ដែលមានលក្ខណៈវិនិច្ឆ័យខាងក្រោម អាចដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ ដោយមិនចាំបាច់ប្រឡង ÷

១- ក្រុមហ៊ុននីតិបុគ្គល ឬក្រុមអាជីវកម្ម ដែលទទួលបានអាជ្ញាប័ណ្ណសេវាកម្មគណនេយ្យនិងសវនកម្ម ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

២- គណនេយ្យករនិងសវនករជំនាញ ដែលជាសមាជិកវិទ្យាស្ថានគណនេយ្យករ និងសវនករជំនាញកម្ពុជា ។

៣- អតីតមន្ត្រីពន្ធដារដែលធ្លាប់បានបំរើការងារនៅរដ្ឋបាលសារពើពន្ធកម្ពុជា ចាប់ពី ១០ឆ្នាំឡើងទៅ និងមិនធ្លាប់ប្រព្រឹត្តបទល្មើសទាក់ទិនពន្ធដារ ឬផ្សំគំនិតជាមួយអ្នកជាប់ពន្ធក្នុងការគេចវេះពន្ធ ឬបន្លំប្រាក់ពន្ធ និងមិនធ្លាប់ទទួលពិន័យផ្សេងៗពីអគ្គនាយកដ្ឋានពន្ធដារ ឬពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬពីតុលាការ។

**ប្រការ ៨.- ការស្នើសុំអាជ្ញាប័ណ្ណ**

១- បុគ្គលដែលមានបំណងធ្វើសកម្មភាពអាជីវកម្មជាភ្នាក់ងារសេវាកម្មពន្ធដារ ត្រូវមានអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ ដែលចេញដោយអគ្គនាយកដ្ឋានពន្ធដារ ។

២- ពាក្យស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ ត្រូវស្នើសុំទៅអគ្គនាយកដ្ឋានពន្ធដារ តាមទម្រង់ និងសេចក្តីណែនាំដែលកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ ។

៣- អ្នកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ ត្រូវបំពេញទម្រង់បែបបទដែលកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម ÷

**ក. រូបវន្តបុគ្គល**

១. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន និងឯកសារបញ្ជាក់អាសយដ្ឋានបច្ចុប្បន្នរបស់បុគ្គលស្នើសុំ

២. លិខិតបញ្ជាក់ថាបានប្រឡងជាប់ជាភ្នាក់ងារសេវាកម្មពន្ធដារ ដែលចេញដោយអគ្គនាយកដ្ឋានពន្ធដារ ។ ដោយឡែកចំពោះ គណនេយ្យករនិងសវនករជំនាញ ត្រូវមានឯកសារបញ្ជាក់ជាសមាជិកវិទ្យាស្ថានគណនេយ្យករ និងសវនករជំនាញកម្ពុជា ។ ចំពោះអតីតមន្ត្រីពន្ធដារ ត្រូវមានឯកសារបញ្ជាក់អតីតភាពពីអគ្គនាយកដ្ឋានពន្ធដារ ថាធ្លាប់បានបម្រើការងារនៅរដ្ឋបាលសារពើពន្ធកម្ពុជា ចាប់ពី ១០ឆ្នាំឡើងទៅ

៣. ឯកសារបញ្ជាក់ទីតាំងដែលធ្វើសកម្មភាពភ្នាក់ងារសេវាកម្មពន្ធដារ

៤. ឯកសារបញ្ជាក់អំពីការចុះបញ្ជីជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស បង់ពន្ធប៉ាតង់ ឬបង់ពន្ធ-អាករផ្សេងៗតាមច្បាប់ត្រឹមត្រូវ

៥. ឯកសារ និងព័ត៌មានផ្សេងៗទៀតពាក់ព័ន្ធចាំបាច់ ។

**ខ. ក្រុមហ៊ុននីតិបុគ្គល ឬក្រុមអាជីវកម្ម**

១. ឯកសារចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម

២. យ៉ាងតិចត្រូវមានអ្នកតំណាងម្នាក់ដែលជានាយក ឬបណ្ណាធិការ ឬកម្មសិទ្ធិករម្នាក់ដែលកាន់កាប់ភាគហ៊ុន ឬសិទ្ធិបោះឆ្នោតលើសពី ៥០% មានលិខិតបញ្ជាក់ថាបានប្រឡងជាប់ជាភ្នាក់ងារសេវាកម្មពន្ធដារ ដែលរៀបចំដោយអគ្គនាយកដ្ឋានពន្ធដារ ។ ដោយឡែក ចំពោះក្រុមហ៊ុននីតិបុគ្គល ឬក្រុមអាជីវកម្មដែលធ្វើសកម្មភាពសេវាកម្មគណនេយ្យនិងសវនកម្ម ត្រូវមានអាជ្ញាប័ណ្ណសេវាកម្មគណនេយ្យនិងសវនកម្ម ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



hz

៣. ឯកសារបញ្ជាក់អំពីការចុះបញ្ជីពន្ធ បង់ពន្ធប៉ាតង់ ឬបង់ពន្ធ-អាករផ្សេងៗតាមច្បាប់ត្រឹមត្រូវ

៤. ឯកសារបញ្ជាក់ទីតាំងដែលធ្វើសកម្មភាពភ្នាក់ងារសេវាកម្មពន្ធដារ

៥. មានប្រវត្តិល្អក្នុងការគោរពប្រតិបត្តិច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ។

**ប្រការ ៩.- សិទ្ធិរបស់ភ្នាក់ងារសេវាកម្មពន្ធដារ**

អនុលោមតាមមាត្រា១០៦ នៃច្បាប់ស្តីពីសារពើពន្ធ ភ្នាក់ងារសេវាកម្មពន្ធដារ ដែលមានលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរធ្វើជាអ្នកតំណាងស្របច្បាប់ពីអ្នកជាប់ពន្ធ មានសិទ្ធិជំនួសមុខឱ្យអ្នកជាប់ពន្ធ ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ ដូចខាងក្រោម ÷

១- ធ្វើទំនាក់ទំនងជាមួយរដ្ឋបាលសារពើពន្ធ

២- បំពេញបែបបទពន្ធដារ

៣- ដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែ ប្រចាំឆ្នាំ និងបង់ពន្ធ-អាករទាំងឡាយ ដែលកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ

៤- ចុះហត្ថលេខាជំនួសអ្នកជាប់ពន្ធ

៥- បង្ហាញនិងផ្តល់ឯកសារ របាយការណ៍ ឬលិខិតយុត្តិការផ្សេងៗពាក់ព័ន្ធនឹងពន្ធដាររបស់អ្នកជាប់ពន្ធដល់រដ្ឋបាលសារពើពន្ធ

៦- ធ្វើបណ្តឹងតវ៉ា និងបណ្តឹងឧទ្ធរណ៍ស្របតាមបទប្បញ្ញត្តិស្តីពីពន្ធដារ

៧- បំពេញរាល់កាតព្វកិច្ចដែលអ្នកជាប់ពន្ធ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ

៨- ទទួលព័ត៌មានជាប្រចាំអំពីការធ្វើបច្ចុប្បន្នភាព ឬវិសោធនកម្មនៃច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ

៩- ធ្វើជាដៃគូសហប្រតិបត្តិការល្អជាមួយរដ្ឋបាលសារពើពន្ធ ក្នុងគោលបំណងដើម្បី ÷

ក. ពង្រីកនិងពង្រឹងការផ្តល់សេវា និងការអប់រំដល់អ្នកជាប់ពន្ធឱ្យទាន់ពេលវេលា និងអាចទុកចិត្តបាន ដើម្បីធានាឱ្យការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារបានល្អប្រសើរ

ខ. ទប់ស្កាត់សកម្មភាពគេចវេះពន្ធ

គ. ផ្តល់អនុសាសន៍សម្រាប់ជាធាតុចូលដើម្បីបំពេញបន្ថែម និងអភិវឌ្ឍន៍ច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងទំនើបកម្ម ។

**ប្រការ ១០.- កាតព្វកិច្ចរបស់ភ្នាក់ងារសេវាកម្មពន្ធដារ**

ភ្នាក់ងារសេវាកម្មពន្ធដារ មានកាតព្វកិច្ច ដូចខាងក្រោម ÷

១- ធ្វើសកម្មភាពអាជីវកម្មភ្នាក់ងារសេវាកម្មពន្ធដារ នៅទីតាំងដែលទទួលបានការអនុញ្ញាតពីអគ្គនាយកដ្ឋានពន្ធដារ ដោយមានដាក់ផ្លាកយីហោជាភ្នាក់ងារសេវាកម្មពន្ធដារ

២- ប្រកាស និងបង់ពន្ធឱ្យបានត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ

៣- ផ្តល់សេវាផ្សេងៗដល់អ្នកជាប់ពន្ធទាក់ទិនពន្ធដារប្រកបដោយវិជ្ជាជីវៈ និងសុចរិតភាព

៤- សម្របសម្រួលដើម្បីឱ្យអ្នកជាប់ពន្ធអនុវត្តបានត្រឹមត្រូវនូវច្បាប់ និងបទប្បញ្ញត្តិនានាស្ដីពីពន្ធដារ

៥- ជួយអ្នកជាប់ពន្ធឱ្យអនុវត្តកាតព្វកិច្ចសារពើពន្ធបានត្រឹមត្រូវ

៦- រួមចំណែកទប់ស្កាត់បទល្មើសគេចបន្លំប្រាក់ពន្ធ តាមរយៈការផ្តល់ព័ត៌មានជូនរដ្ឋបាលសារពើពន្ធអំពីសកម្មភាពគេចវេះពន្ធ

៧- ផ្តល់លិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីអតិថិជនរបស់ខ្លួន និងបង្ហាញប័ណ្ណសម្គាល់ភ្នាក់ងារសេវាកម្មពន្ធដារ ជូនមន្ត្រីពន្ធដារក្នុងពេលបំពេញភារកិច្ចជាតំណាងស្របច្បាប់របស់អ្នកជាប់ពន្ធ

៨- ទំនាក់ទំនង ឬធ្វើការជាមួយរដ្ឋបាលសារពើពន្ធប្រកបដោយភាពស្មោះត្រង់

៩- ផ្តល់ឯកសារ កំណត់ត្រា បញ្ជីគណនេយ្យ និងព័ត៌មានផ្សេងៗទៀតទាក់ទិនសកម្មភាពអាជីវកម្មរបស់អតិថិជន តាមសំណើរបស់រដ្ឋបាលសារពើពន្ធ

១០-មិនត្រូវបង្ហាញ និងផ្តល់ព័ត៌មានសម្ងាត់នានាទាក់ទិនពន្ធដារ របស់អតិថិជនខ្លួនទៅតតិយជន ដោយគ្មានការអនុញ្ញាតពីអតិថិជនខ្លួនឡើយ លើកលែងតែមន្ត្រីពន្ធដារក្នុងពេល និងក្នុងគោលដៅបំពេញភារកិច្ចជាផ្លូវការតាមបទប្បញ្ញត្តិស្ដីពីពន្ធដារ

១១-ផ្តល់ជូនអគ្គនាយកដ្ឋានពន្ធដារនូវបញ្ជីឈ្មោះបុគ្គលិក ដែលធ្វើការទាក់ទិនការផ្តល់សេវាកម្មពន្ធដារជារៀងរាល់ឆ្នាំ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣១ ខែមីនា នៃឆ្នាំបន្ទាប់

១២-បន្តបង្កើននិងធ្វើបច្ចុប្បន្នភាពចំណេះដឹង និងជំនាញទាក់ទិនវិជ្ជាជីវៈរបស់ខ្លួន ដើម្បីធានាថា សេវាកម្មដែលត្រូវបានផ្តល់ឱ្យអតិថិជន ប្រកបដោយវិជ្ជាជីវៈ ត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានាស្ដីពីពន្ធដារជាធរមាន ។

**ប្រការ ១១.- អាជ្ញាយុកាលនៃអាជ្ញាប័ណ្ណ និង ការសុំអាជ្ញាប័ណ្ណបន្ត**

១- អាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ ត្រូវចេញដោយអគ្គនាយកដ្ឋានពន្ធដារ ហើយអាជ្ញាប័ណ្ណនេះមានសុពលភាពរយៈពេល ២ឆ្នាំ ។

២- បុគ្គលដែលកាន់អាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ ត្រូវដាក់ពាក្យស្នើសុំបន្តអាជ្ញាប័ណ្ណក្នុងរយៈពេលយ៉ាងយឺតបំផុត ៣០ថ្ងៃ មុនរយៈពេលដែលអាជ្ញាប័ណ្ណចាស់អស់សុពលភាព ។ ពាក្យស្នើសុំបន្តអាជ្ញាប័ណ្ណ ត្រូវដាក់ជូនអគ្គនាយកដ្ឋានពន្ធដារតាមទម្រង់ និងភ្ជាប់មកជាមួយនូវឯកសារនានាដូចមានចែងក្នុងប្រការ៨ នៃប្រកាសនេះ ។

៣- បុគ្គលដែលជាភ្នាក់ងារសេវាកម្មពន្ធដារ គ្មានសិទ្ធិបន្តប្រកបអាជីវកម្មជាភ្នាក់ងារសេវាកម្មពន្ធដារឡើយ ប្រសិនបើអាជ្ញាប័ណ្ណដែលបុគ្គលនោះកាន់កាប់ផុតសុពលភាព ហើយបុគ្គលនោះមិនបានដាក់ពាក្យស្នើសុំបន្តអាជ្ញាប័ណ្ណសាជាថ្មី ។

៤- បុគ្គលដែលទទួលបានអាជ្ញាប័ណ្ណជាភ្នាក់ងារសេវាកម្មពន្ធដារ អាចបើកសាខា ឬការិយាល័យធ្វើអាជីវកម្មភ្នាក់ងារសេវាកម្មពន្ធដារលើសពីមួយកន្លែង តាមការអនុញ្ញាតពីអគ្គនាយកដ្ឋានពន្ធដារ ដោយមានដាក់ផ្លាកយីហោជាសាខា ឬការិយាល័យភ្នាក់ងារសេវាកម្មពន្ធដារ នៅទីតាំងទាំងនោះ ។

## ប្រការ ១២.- ការបដិសេធ និងការតវ៉ាពាក្យស្នើសុំអាជ្ញាប័ណ្ណ

ពាក្យស្នើសុំអាជ្ញាប័ណ្ណអាចត្រូវបានបដិសេធ ប្រសិនបើបុគ្គលស្នើសុំមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមលក្ខណៈវិនិច្ឆ័យដូចមានចែងក្នុងប្រការ៧ និងប្រការ៨ នៃប្រកាសនេះ ។ ក្រោយពេលទទួលបាននូវសេចក្តីជូនដំណឹងពីការបដិសេធ បុគ្គលស្នើសុំអាចតវ៉ាទៅអគ្គនាយកដ្ឋានពន្ធដារ ដើម្បីសុំពិនិត្យឡើងវិញនូវសេចក្តីសម្រេចបដិសេធនោះ ដោយបញ្ជាក់នូវមូលហេតុ និងភស្តុតាងបន្ថែមនានា ។

## ប្រការ ១៣.- ការផ្លាស់ប្តូរនាយក ឬបណ្ណាធិការ ឬកម្មសិទ្ធិករ

ក្នុងករណីភ្នាក់ងារសេវាកម្មពន្ធដារជាក្រុមហ៊ុននីតិបុគ្គល ឬក្រុមអាជីវកម្ម មានការផ្លាស់ប្តូរនាយក ឬបណ្ណាធិការ ឬកម្មសិទ្ធិករម្នាក់ដែលកាន់កាប់ភាគហ៊ុនឬសិទ្ធិបោះឆ្នោតលើសពី ៥០% ដែលប្រឡងជាប់ភ្នាក់ងារសេវាកម្មពន្ធដារ ក្រុមហ៊ុននីតិបុគ្គល ឬក្រុមអាជីវកម្មនោះត្រូវជូនដំណឹងអំពីការផ្លាស់ប្តូរមក អគ្គនាយកដ្ឋានពន្ធដារ យ៉ាងយឺតបំផុត ៣០ថ្ងៃ មុនការផ្លាស់ប្តូរ ។

## ប្រការ ១៤.- កម្រៃអាជ្ញាប័ណ្ណ

១- នៅពេលដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ ឬអាជ្ញាប័ណ្ណបន្ត ភ្នាក់ងារសេវាកម្មពន្ធដារ ត្រូវបង់កម្រៃអាជ្ញាប័ណ្ណជូនអគ្គនាយកដ្ឋានពន្ធដារ ចំនួន ១.០០០.០០០ រៀល (មួយលានរៀល) ចំពោះរូបវន្តបុគ្គល និងចំនួន ២.០០០.០០០ រៀល (ពីរលានរៀល) ចំពោះក្រុមហ៊ុននីតិបុគ្គល និងក្រុមអាជីវកម្ម ។

២- ភ្នាក់ងារសេវាកម្មពន្ធដារដែលបើកសាខាឬការិយាល័យ ធ្វើអាជីវកម្មភ្នាក់ងារសេវាកម្មពន្ធដារ ត្រូវបង់កម្រៃបន្ថែមដោយឡែកចំនួន ៥០០.០០០រៀល (ប្រាំសែនរៀល) សម្រាប់សាខាឬការិយាល័យនីមួយៗ ចំពោះរូបវន្តបុគ្គល និង ១.០០០.០០០រៀល (មួយលានរៀល) សម្រាប់សាខាឬការិយាល័យនីមួយៗ ចំពោះក្រុមហ៊ុននីតិបុគ្គល និងក្រុមអាជីវកម្ម ។

៣- កម្រៃអាជ្ញាប័ណ្ណដែលបានបង់ហើយ មិនត្រូវបានបង្វិលសងវិញឡើយ ។

## ប្រការ ១៥.- ការព្យួរ និងការលុបចោលអាជ្ញាប័ណ្ណ

អគ្គនាយកដ្ឋានពន្ធដារ អាចព្យួរទុក ឬលុបចោល នូវអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ ក្នុងករណី ដែលភ្នាក់ងារសេវាកម្មពន្ធដារ ÷

១- ខកខានមិនអនុវត្តបានត្រឹមត្រូវតាមប្រកាសនេះ

២- ល្មើសច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ

៣- ធ្វើ ឬផ្តល់យោបល់ ឬចូលរួមជាមួយអតិថិជន ក្នុងសកម្មភាពលួចបន្លំប្រាក់ពន្ធ

៤- ផ្តល់យោបល់ ឬផ្តល់សេវាផ្សេងៗដល់អតិថិជនមិនត្រឹមត្រូវ ដែលនាំឱ្យអតិថិជនប្រព្រឹត្តខុសច្បាប់និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ

៥- មានចេតនាធ្វើឱ្យរាំងស្ទះដល់ការកំណត់ពន្ធ និងការប្រមូលពន្ធ

៦- កេងបន្លំប្រាក់ពន្ធស្ថាប័នរដ្ឋ និងអតិថិជន

៧- ជាប់បំណុលមិនអាចសងរួច ឬក្ស័យធន

៨- បាត់បង់សមត្ថភាព ដោយមូលហេតុផ្សេងៗដែលមិនអាចបំពេញឱ្យបានត្រឹមត្រូវនូវកាតព្វកិច្ច និងការទទួលខុសត្រូវរបស់ខ្លួនជាភ្នាក់ងារសេវាកម្មពន្ធដារ

៩- ប្រព្រឹត្តល្មើសច្បាប់ និងបទប្បញ្ញត្តិនានាជាធរមាន ដែលមានកម្រិតធ្ងន់ធ្ងរ

១០- ឈប់ធ្វើអាជីវកម្មជាភ្នាក់ងារសេវាកម្មពន្ធដារ

ការព្យួរ ឬការលុបចោលអាជ្ញាប័ណ្ណជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ មិនត្រូវបានផ្តល់នូវសំណង ឬជម្ងឺចិត្តឡើយ ។

**ប្រការ ១៦.- បទល្មើស និងទោសទណ្ឌ**

១- ភ្នាក់ងារសេវាកម្មពន្ធដារ ត្រូវទទួលរងនូវទោសទណ្ឌ ដូចខាងក្រោម ក្នុងករណី ÷

ក. ធ្វើសកម្មភាពអាជីវកម្មជាភ្នាក់ងារសេវាកម្មពន្ធដារ ឬបើកសាខាឬការិយាល័យ នៅទីតាំងដែលគ្មានការអនុញ្ញាតពីអគ្គនាយកដ្ឋានពន្ធដារ ត្រូវទទួលរងពិន័យស្មើនឹង ១០.០០០.០០០ រៀល (ដប់លានរៀល) និង/ឬ ផ្អាកជាបណ្តោះអាសន្នសកម្មភាពអាជីវកម្មភ្នាក់ងារសេវាកម្មពន្ធដាររយៈពេល ៦ខែ ។

ខ. ប្រើប្រាស់អាជ្ញាប័ណ្ណហួសសុពលភាព ត្រូវទទួលរងពិន័យស្មើនឹងពីរដង នៃកម្រៃអាជ្ញាប័ណ្ណត្រូវបង់ បូកនឹងការប្រាក់ ២% ក្នុងមួយខែ គិតចាប់ពីខែបន្ទាប់ពីខែដែលកម្រៃអាជ្ញាប័ណ្ណត្រូវបង់ និង/ឬ ផ្អាកសកម្មភាពអាជីវកម្មភ្នាក់ងារសេវាកម្មពន្ធដារ រយៈពេល ៣ខែ ។

២- ភ្នាក់ងារសេវាកម្មពន្ធដារ ដែលប្រព្រឹត្តល្មើសដូចមានចែងក្នុងកថាខណ្ឌ១ ដល់ ៦ នៃប្រការ ១៥ នៃប្រកាសនេះ ត្រូវរងពិន័យជាប្រាក់ ៥.០០០.០០០ រៀល (ប្រាំលានរៀល) ឬផ្អាកសកម្មភាពអាជីវកម្មភ្នាក់ងារសេវាកម្មពន្ធដារ រយៈពេលពី ៣ខែ ដល់ ១ឆ្នាំ ឬដកហូតអាជ្ញាប័ណ្ណបញ្ឈប់សកម្មភាពអាជីវកម្មភ្នាក់ងារសេវាកម្មពន្ធដារជាស្ថាពរ ។

៣- បុគ្គល ដែលពុំមែនជាភ្នាក់ងារសេវាកម្មពន្ធដារ ធ្វើអាជីវកម្មភ្នាក់ងារសេវាកម្មពន្ធដារ ដោយគ្មានអាជ្ញាប័ណ្ណ ត្រូវចាត់ទុកថាប្រព្រឹត្តអំពើរាំងស្ទះដូចមានចែងក្នុងមាត្រា១២៨ និងត្រូវទទួលរងការផ្តន្ទាទោសតាមមាត្រា១៣៦ នៃច្បាប់ស្តីពីសារពើពន្ធ ដោយពិន័យជាប្រាក់ពី ៥.០០០.០០០ រៀល (ប្រាំលានរៀល) ដល់ ១០.០០០.០០០ រៀល (ដប់លានរៀល) ឬជាប់ពន្ធនាគារពី ១ ខែ ដល់ ១ ឆ្នាំ ឬទោសទាំងពីរនេះ ចំពោះរូបវន្តបុគ្គល ឬអ្នកទទួលខុសត្រូវរបស់ក្រុមហ៊ុននីតិបុគ្គល និងក្រុមអាជីវកម្ម រួមមាន នាយក ឬបណ្ណាធិការ ឬកម្មសិទ្ធិករម្នាក់ដែលកាន់កាប់ភាគហ៊ុន ឬសិទ្ធិបោះឆ្នោតលើសពី ៥០% ។

៤- អ្នកជាប់ពន្ធតាមរបបពិត ដែលទទួលការផ្គត់ផ្គង់សេវាកម្មពន្ធដារ ពីបុគ្គលដែលពុំមែនជាភ្នាក់ងារសេវាកម្មពន្ធដារ ដែលធ្វើអាជីវកម្មភ្នាក់ងារសេវាកម្មពន្ធដារដោយគ្មានអាជ្ញាប័ណ្ណ ត្រូវរងពិន័យជាប្រាក់ ៥.០០០.០០០ រៀល (ប្រាំលានរៀល) ។

៥- អ្នកជាប់ពន្ធតាមរបបម៉ៅការ អាចទទួលបានការផ្គត់ផ្គង់សេវាទាក់ទិនពន្ធដារ ដោយបុគ្គលដែលគ្មានអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ ដោយពុំទទួលរងពិន័យដូចមានចែងក្នុងកថាខណ្ឌ៤ នៃប្រការនេះ ចំពោះប្រភេទពន្ធមួយចំនួនដែលមិនស្ថិតនៅក្នុងកាតព្វកិច្ចបង់ពន្ធរបស់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដូចជា អាករ



VK

លើផលរបរ អាករពិសេសលើទំនិញនិងសេវាមួយចំនួន អាករបំភ្លឺសាធារណៈ អាករស្នាក់នៅ ពន្ធលើអចលនទ្រព្យ ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានយន្តគ្រប់ប្រភេទ ពន្ធលើឈ្នួលផ្ទះនិងដី ពន្ធប្រថាប់ត្រា ពន្ធសត្តឃាត ពន្ធប៉ាតង់ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងពន្ធតែមប្រិ៍ ។

**ប្រការ ១៧.- ប្រសិទ្ធភាពនៃការអនុវត្ត**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីកាលបរិច្ឆេទដែលអគ្គនាយកដ្ឋានពន្ធដារ ចេញអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ ជាផ្លូវការជូនបេក្ខជនដែលប្រឡងជាប់ជាភ្នាក់ងារសេវាកម្មពន្ធដារដំបូង ។

**ប្រការ ១៨.- ការអនុវត្ត**

អគ្គលេខាធិការ នាយកខុទ្ទកាល័យនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ប្រធាននាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងបុគ្គលដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

គាត ឈន់

**ចម្លងជូន ÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់សាលារាជធានី-ខេត្ត "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "ដើម្បីអនុវត្ត" (ដូចប្រការ ១៨)
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ